ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៤១១៨ សជណ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារតាមដានការអនុវត្តគោលការណ៍ណែនាំរបស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/០២៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្ស ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៣០៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ
- យោងតាមការងារចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.-**

បង្កើត ក្រុមការងារតាមដានការអនុវត្តគោលការណ៍ណែនាំរបស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- បណ្ឌិត | **ទូច សុខៈ** | អ្នកនាំពាក្យរងក្រសួងមហាផ្ទៃ | ប្រធាន |
| ២- លោក | **រ៉េន រតនៈ** | អ្នកនាំពាក្យ ឯកឧត្តមអភិសន្តិបណ្ឌិត | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣- លោកស្រី **ឈឹម ខឹមហួន** | ជំនួយការ ឯកឧត្តមអភិសន្តិបណ្ឌិត | | អនុប្រធាន |
| ៤- លោក **លី សៅ** | ជំនួយការ ឯកឧត្តមអភិសន្តិបណ្ឌិត | | សមាជិក |
| ៥- កញ្ញា **រី ស្រីណាត** | ជំនួយការ ឯកឧត្តមអភិសន្តិបណ្ឌិត | | សមាជិក |
| ៦- លោក **ឆឹង ឆលាង** | ជំនួយការ ឯកឧត្តមអភិសន្តិបណ្ឌិត | | សមាជិក |
| ៧- លោក **ធឿន តារុន** | មន្ត្រីខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត | | សមាជិក |
| ៨- លោក **ស លីសាន់** | មន្ត្រីខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត | | សមាជិក។ |

**ប្រការ២.-**

ក្រុមការងារតាមដាននេះ មានតួនាទីជាសេនាធិការផ្ទាល់របស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដោយមានភារកិច្ចដូចខាងក្រោម៖

- ប្រមូល និងរៀបចំជាបញ្ជីពល់អនុសាសន៍របស់**ឯកឧត្តមអភិសន្តិបណ្ឌិត** ទាំងលិខិត និងផ្ទាល់មាត់
- តាមដាន ពិនិត្យ វាយតម្លៃ ជំរុញការអនុវត្ត និងលើកយោបល់គោរពជូន**ឯកឧត្តមអភិសន្តិបណ្ឌិត**
- តាមដាន វាយតម្លៃមតិត្រឡប់ពីមន្ត្រីចំណុះក្រសួងមហាផ្ទៃ និងមហាជនទូទៅ ចំពោះគោលការណ៍ណែនាំរបស់**ឯកឧត្តមអភិសន្តិបណ្ឌិត**
- ទំនាក់ទំនងជាមួយអគ្គនាយកដ្ឋាន អង្គភាពនានាចំណុះក្រសួងមហាផ្ទៃ រដ្ឋបាលថ្នាក់ក្រោមជាតិ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងភាគីពាក់ព័ន្ធនានា
- រៀបចំកិច្ចប្រជុំ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពការងារប្រចាំខែ ឆមាស និងប្រចាំឆ្នាំ គោរពជូន**ឯកឧត្តមអភិសន្តិបណ្ឌិត**
- រៀបចំផែនការសកម្មភាពការងារ និងហិរញ្ញវត្ថុរបស់ក្រុមការងារ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់របស់**ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។

**ប្រការ៣.-**

ក្រុមការងារនេះ មានថវិកាសម្រាប់ដំណើរការការងាររបស់ខ្លួនស្ថិតនៅក្នុងកញ្ចប់ថវិការបស់ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ៤.-**

រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃ អគ្គនាយកដ្ឋានរដ្ឋបាល ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននិងសន្តិសុខសាយប័រ អគ្គលេខាធិការនៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា[illegible]ក្រសួង

មហាផ្ទៃ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ លេខាធិការនៃលេខាធិការដ្ឋាន គ.ប.ផ.ក និងសាមីខ្លួន ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧រោច ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ